THE SCHOOL DISTRICT OF PHILADELPHIA

# អ្វីៗដែលក្រុមគ្រួសារអាចធ្វើ

## ដើម្បីគាំទ្រដល់ភាពជោគជ័យនៃការបញ្ចប់ការសិក្សារបស់កូនគាត់



មិនថាកូនរបស់លោកអ្នកមានអាយុប៉ុន្មានទេ មិនដែលលឿនពេកទេក្នុងការចាប់ផ្តើមគិតអំពីផ្លូវទៅកាន់ការបញ្ចប់ការសិក្សារបស់ពួកគេ។ នេះជាអ្វីៗមួយចំនួនដែលលោកអ្នកអាចធ្វើ ដើម្បីគាំទ្រកូនរបស់លោកអ្នកក្នុងការបញ្ចប់ការសិក្សារបស់ពួកគេ។

### 1 គាំទ្រកូនរបស់លោកអ្នកឱ្យទៅរៀនឱ្យបានទៀងទាត់។

សិស្សដែលទៅរៀនទៀងទាត់អាចអានបានតាមកម្រិតថ្នាក់ និងបញ្ចប់ការសិក្សាទាន់ពេល។

### 2 ដឹង និងយល់ ពីតម្រូវការនៃការបញ្ចប់ការសិក្សា។

សូមមើលគេហទំព័រ philasd.org/gradreq ដើម្បីពិនិត្យមើលតម្រូវការទាំងនោះ។ ប្រើប្រភពជំនួយផ្សេងៗដើម្បីបង្កើត ផែនការបញ្ចប់ការសិក្សា ក្នុងភាពជាដៃគូជាមួយកូនលោកអ្នក។

### 3 សូមចុះឈ្មោះសម្រាប់ គេហទំព័រសម្រាប់មាតាបិតា (Parent Portal) ហើយមើលគណនីរបស់លោកអ្នកឱ្យបានញឹកញាប់។

Parent Portal គឺជាមធ្យោបាយដ៏ល្អបំផុតដើម្បីតាមដានការរីកចម្រើន ពិន្ទុ វត្តមានអវត្តមាន និងអ្វីៗជាច្រើនទៀត របស់កូនលោកអ្នក។ ក៏ជាមធ្យោបាយដ៏ល្អបំផុតក្នុងការទទួលបានព័ត៌មានថ្មីៗពីក្រសួងអប់រំ ផងដែរ។ គ្មានគណនី Parent Portal មែនទេ? សូមចូលទៅកាន់គេហទំព័រ philasd.org/pfportal ដើម្បីស្វែងយល់បន្ថែម និងចុះឈ្មោះ។

### 4 ចូលរួមក្នុងអង្គប្រជុំចែកបាយការណ៍ពិន្ទុ។

ឆក់យកអត្ថប្រយោជន៍ពីអង្គប្រជុំ និងឱកាសផ្សេងៗទៀត ដើម្បីចូលរួមជាមួយគ្រូរបស់កូនលោកអ្នក ហើយពិភាក្សាឱ្យបានច្រើនអំពីការរីកចម្រើនរបស់កូនលោកអ្នក។ ដើម្បីស្វែងរកកាលបរិច្ឆេទនៃអង្គប្រជុំនាពេលខាងមុខ សូមមើលគេហទំព័ philasd.org/calendar។

### 5 ស្វែងរកឱកាសសិក្សា និងពង្រឹងសមត្ថភាព។

ក្រសួងអប់រំផ្តល់ឱកាសជាច្រើនតាមរយៈសាលារៀន ឬតាមរយៈការិយាល័យកណ្តាល។ ពិភាក្សាជាមួយកូនរបស់លោកអ្នកអំពីឱកាសផ្សេងៗដើម្បីបង្កើនការរៀនសូត្ររបស់ពួកគេ និងស្វែងរកសកម្មភាពដែលស្របតាមអ្វីៗដែលពួកគេចាប់អារម្មណ៍ និងត្រូវការ រួមមាន៖ ជម្រើសនៃការជួយបង្រៀនបន្ថែម កម្មវិធីរៀនបង្គ្រប់ពិន្ទុ កម្មវិធីក្រៅកម្មវិធីសិក្សា កម្មវិធីក្នុងរដូវក្តៅ និងប្រភពជំនួយផ្សេងៗទៀត។ សូមចាំថា ត្រូវពិចារណាអំពីប្រភពជំនួយ និងឱកាសផ្សេងៗ សម្រាប់សិស្សដែលត្រូវរៀនភាសាអង់គ្លេស និងសិស្សដែលមានគម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ។

### 6 សួរសំណួររបស់លោកអ្នក!

ប្រសិនបើលោកអ្នកមានសំណួរអំពីការរីកចម្រើនរបស់កូនលោកអ្នក សូមទាក់ទងទៅការិយាល័យសាលាដោយផ្ទាល់ ហើយស្នើសុំការជួបប្រជុំ។ សូមមើលគេហទំព័រ philasd.org/face/gethelp ដើម្បីស្វែងរកព័ត៌មានសម្រាប់ទាង់ទងរបស់សាលាលោកអ្នក។

ស្វែងរកតម្រូវការជាក់លាក់អំពីការបញ្ចប់ការសិក្សានីមួយៗ ព្រមទាំងប្រភពជំនួយផ្សេងៗ
និងព័ត៌មានបន្ថែម នៅគេហទំព័រ **philasd.org/gradreq**

នៅតែមានសំណួរឬ? អ៊ីមែល gradreq@philasd.org (Khmer)